# ព្រឹត្តិបត្រព័ត៌មាន

គម្រោងអភិវឌ្ឍន៍សុខភាពសិក្សាសម្រាប់កុមារកម្ពុជា

ការបោះពុម្ពពិសេស | ថ្ងៃពុធ ២រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹង ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤

## មតិស្វាគមន៍ពីសាស្ត្រាចារ្យបណ្ឌិត អាសាគឺរ៉ា តាកាស៊ី

ការបោះពុម្ពផ្សាយពិសេសនេះគឺជាការចងក្រងនៃសុន្ទរកថារបស់សាស្ត្រាចារ្យបណ្ឌិត អាសាគឺរ៉ា តាកាស៊ី នៅក្នុងពិធីបើកវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសសុខភាពសិក្សាលើកទី ១៨ កាលពីខែកក្កដា ឆ្នាំ២០២៤ នេះ។

## ការអប់រំដើម្បីអភិវឌ្ឍសមត្ថភាពអវិជ្ជមានដើម្បីរស់ក្នុងយុគសម័យ VUCA

ថ្ងៃនេះខ្ញុំចង់និយាយពាក់ព័ន្ធនឹងពីរចំណុចគឺ៖ តើអ្វីជាប្រសិទ្ធភាពនៃការបង្រៀននិងការអប់រំ ព្រមទាំងការវាយតម្លៃនៃការអប់រំនិងសមត្ថភាពដែលគួរអភិវឌ្ឍក្នុងវិស័យអប់រំ។ ខ្ញុំបានសង្កេតមើលថ្នាក់សុខភាពនៅអនុវិទ្យាល័យចំនួន ៩ ដែលជាផ្នែកមួយនៃគម្រោងគំរូរបស់អង្គការគីហ្សូណានៅខេត្តកោះកុង។ ថ្នាក់សុខភាពនោះបានបង្រៀនអំពីជំងឺឆ្លងដោយមានការសន្និដ្ឋានថា ប្រសិនបើមានចំណេះដឹងនោះជំងឺឆ្លងអាចនឹងត្រូវបានបង្ការ។



### របៀបក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការបង្រៀនមេរៀន

ខ្ញុំចង់ចែករំលែកយោបល់របស់ខ្ញុំអំពីការវាយតម្លៃក្នុងវិស័យអប់រំ និងសមត្ថភាពដែលគួរត្រូវបានអភិវឌ្ឍរបស់សិស្សានុសិស្ស និងកូនសិស្សដោយផ្អែកលើចំណាប់អារម្មណ៍របស់ខ្ញុំទទួលបានពីដំណើរទស្សនកិច្ចនោះ។ ទីមួយទាក់ទងនឹងការអប់រំ ជាពិសេសអំពីរបៀបក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការបង្រៀនមេរៀន។ ការស្រាវជ្រាវលើមេរៀនមានគោលបំណងស្វែងរកការកែលម្អ ដើម្បីធ្វើឱ្យការបង្រៀនកាន់តែប្រសើរឡើង និងដើម្បីធានាថាមានផលវិជ្ជមានកើតឡើងសម្រាប់អ្នកសិក្សានៅក្នុងថ្នាក់។ ខណៈពេលដែលមានសំណួរសំខាន់ៗមួយចំនួនលើកឡើងថា «តើអ្វីជាមេរៀនល្អមួយ?» ខ្ញុំនឹងនិយាយនៅទីនេះអំពីរបៀបក្នុងការវាយតម្លៃផលប៉ះពាល់នៃការអប់រំដែលកើតឡើងលើអ្នកសិក្សា ជាពិសេសលើសិស្សានុសិស្ស និងកូនសិស្ស។







ម្យ៉ាងវិញទៀត ការសង្កេតក្នុងថ្នាក់ដោយផ្ទាល់ ឬដោយប្រយោល និងការស្តាប់ពីបទពិសោធន៍របស់គ្រូបង្រៀន កូនសិស្ស និងសិស្សានុសិស្សអាចត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃមេរៀន។ វាទាមទារឱ្យមានការស្រាវជ្រាវវាយតម្លៃមេរៀនបែបគុណវិស័យ (qualitative lesson evaluation research) ។ នេះគឺជាដំណើរការនៃការវាយតម្លៃ។ ប៉ុន្តែជាដំបូង តើយើងអាចអះអាងពីហេតុប៉ះពាល់នៃការអប់រំ និងការបង្រៀនលើកូនសិស្ស និងសិស្សានុសិស្សដោយវិធីសាស្ត្របរិមាណវិស័យ ឬគុណវិស័យដែរឬទេ? តើទស្សនវិស័យក្នុងការវាយតម្លៃមិនផ្អែកលើនិន្នាការបច្ចុប្បន្ននៅក្នុងវិស័យអប់រំ គោលបំណងគោលនយោបាយរបស់រដ្ឋបាលអប់រំ ឬភាពងាយស្រួលរបស់គ្រូបង្រៀន និងសាលារៀនទេ ប៉ុន្តែបែរជាផ្អែកលើទស្សនៈដែលផ្តោតសំខាន់លើការលូតលាស់របស់ធនធានមនុស្ស និងការអភិវឌ្ឍរបស់សិស្សានុសិស្ស និងគ្រូជាមុនទៅវិញ?

## ប្រសិទ្ធភាពត្រូវតែ «**អាចវាស់វែងបាន**» ?

ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការបង្រៀន ការអប់រំ និងការសិក្សា ជាទូទៅគេសន្មត់ថា ប្រសិទ្ធភាពអាចត្រូវបានវាយតម្លៃជាបរិមាណបាន។ នៅក្នុងន័យមួយទៀត វាត្រូវតែ «អាចវាស់វែងបាន»។ ដើម្បីធ្វើដូច្នេះបាន ចាំបាច់ត្រូវបង្កើតសូចនាករដែលអាចកំណត់បរិមាណព្រឹត្តិការណ៍ដែលបង្ហាញពីប្រសិទ្ធភាព និងអាចធ្វើការវាស់វែងបាន។ វិធីសាស្ត្រសម្រាប់វាស់វែងតម្រូវឱ្យបង្កើតឡើង។ នេះគឺជាគំនិតនៃការស្រាវជ្រាវវាយតម្លៃមេរៀនបែបបរិមាណវិស័យ។ ទាំងនេះត្រូវបានគេហៅថា «ការវាយតម្លៃលទ្ធផល» ។



វាចាំបាច់ត្រូវមានទិដ្ឋភាពដែលអាចបកស្រាយបានទាំងស្រុងអំពីប្រសិទ្ធភាពនៃការអប់រំនិងការបង្រៀនដែលអាចវាស់វែង និងពណ៌នាបាន ក៏ដូចជាទិដ្ឋភាពដែលមិនអាចបកស្រាយបាន ពោលគឺមិនអាចកំណត់បរិមាណឬពណ៌នាបាន។ យើងមិនអាចវាយតម្លៃការអប់រំនិងការបង្រៀនបានដោយផ្អែកតែលើអ្វីដែលងាយវាស់វែងនិងដែលលេចឡើងតែនៅផ្ទៃសើរៗនៃការយល់ដឹងនិងអាកប្បកិរិយានោះទេ។ វាអាចងាយស្រួលសម្រាប់សិស្ស ដើម្បីយល់ពីសារៈសំខាន់នូវអ្វីដែលគាត់រៀននៅក្នុងថ្នាក់ខណៈពួកគាត់កាន់តែលូតលាស់ធំឡើង ទោះបីជាគាត់មិនយល់វានៅពេលនោះក៏ដោយ។ ជាការពិតណាស់ ទិដ្ឋភាពដែលអាចយល់បានគឺមានសារៈសំខាន់ចំពោះការវាយតម្លៃការអប់រំ ប៉ុន្តែអ្នកអប់រំនិងគ្រូបង្រៀនត្រូវចងចាំនូវទស្សនៈទាំងពីរនៅក្នុងចិត្ត។ តាមរយៈការគិតនេះ យើងជឿថា វាមានសារៈសំខាន់ណាស់ដែលមិនត្រូវពេញចិត្តនឹងចម្លើយត្រឹមត្រូវសើរៗដែលផ្តល់ឱ្យដោយកូនសិស្សនិងសិស្សានុសិស្សនោះទេ ប៉ុន្តែត្រូវអនុវត្តនិងវាយតម្លៃមេរៀន ខណៈធ្វើលំហាត់ការស្រមើលស្រមៃរបស់យើងលើអ្វីដែលកំពុងកើតឡើងឬមិនកើតឡើងនៅក្នុងជម្រៅចិត្តរបស់ពួកគេ។








ឧទាហរណ៍ ប្រសិនបើសិស្សឆ្លើយថា ការពាក់អាវដៃវែង និងខោជើងវែង គឺជាវិធីបង្ការមូសខាំដើម្បីបង្ការការឆ្លងមេរោគនានាដែលចម្លងដោយមូស ប៉ុន្តែជាក់ស្តែងគាត់ពាក់អាវដៃខ្លី ខោខ្លី ឬសំពត់ទៅវិញ តើនឹងមានអ្វីកើតឡើងចំពោះពួកគេ? ប្រសិនបើសិស្សឆ្លើយថា ការទទួលទានអាហារូបត្ថម្ភនិងបន្លែឱ្យបានគ្រប់គ្រាន់មានសារៈសំខាន់ក្នុងការបង្កើនភាពស៊ាំ ប៉ុន្តែស្ថានភាពសេដ្ឋកិច្ចក្នុងគ្រួសាររបស់គាត់មិនអនុញ្ញាតឱ្យគាត់បរិភោគអាហារនិងបន្លែដែលមានតុល្យភាពទេនោះ តើនឹងមានអ្វីកើតឡើងចំពោះគាត់ក្នុងលក្ខខណ្ឌនៃថ្នាក់រៀននិងការអប់រំនៅពេលនោះ? ការអប់រំសុខភាពជារឿយៗប្រឈមនឹងភាពប្រផាំងគ្នាបែបនេះ។ យើងត្រូវចោទសួរថាតើ យើងអាចប្រើប្រាស់ភាពប្រផាំងគ្នាទាំងនេះបែបណាទៅក្នុងការបង្រៀនរបស់យើងដើម្បីធ្វើឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាព។ ចំណុចមួយទៀតគឺពាក់ព័ន្ធនឹងសមត្ថភាពដែលគួរលើកស្ទួយក្នុងការអប់រំនិងការបង្រៀន។ ខ្ញុំនឹងនិយាយអំពីសមត្ថភាពវិជ្ជមាន និងសមត្ថភាពអវិជ្ជមាន។



## យុគសម័យ VUCA




តើអ្នកធ្លាប់ឮពាក្យ VUCA ដែលផ្តុំឡើងដោយអក្សរ V, U, C, និង A ដែរឬទេ? ពាក្យនេះត្រូវបានបង្កើតឡើងដោយអក្សរដំបូងនៃពាក្យជាភាសាអង់គ្លេសដែលតំណាងឱ្យស្ថានភាពនៃពិភពលោកសព្វថ្ងៃនេះ៖

- V តំណាងឱ្យ «Volatility - ភាពប្រែប្រួល» មានន័យថា កិច្ចការពិភពលោកមានគឺអាចប្រែប្រួល និងផ្លាស់ប្តូរបាន។
- U តំណាងឱ្យ «Uncertainty - ភាពមិនប្រាកដប្រជា» មានន័យថា អ្វីដែលនឹងកើតឡើងនៅក្នុងពិភពលោកនាពេលអនាគតគឺមិនប្រាកដប្រជា និងមិនអាចទស្សន៍ទាយទុកមុនបាន។
- C តំណាងឱ្យ «Complexity - ភាពស្មុគស្មាញ» មានន័យថា អ្វីដែលកំពុងកើតឡើងនៅក្នុងពិភពលោកគឺស្មុគស្មាញ និងពិបាកយល់ដោយសារកត្តាផ្សេងៗជាច្រើន។
- A តំណាងឱ្យ «Ambiguity - ភាពមិនច្បាស់លាស់» មានន័យថា ហេតុនិងផលនៃព្រឹត្តិការណ៍នៅក្នុងពិភពលោកគឺមិនច្បាស់លាស់។

នៅប្រទេសជប៉ុន និងបណ្តាប្រទេសលោកខាងលិចជាច្រើនទៀត សមត្ថភាពដែលពួកគេកំពុងស្វែងរកសម្រាប់កុមារនិងយុវជនដែលនឹងដឹកនាំអនាគតខាងមុខគឺជាសមត្ថភាពដែលអាចឱ្យពួកគេរស់រានមានជីវិត និងអភិវឌ្ឍសង្គមឱ្យកាន់តែប្រសើរឡើងក្នុងយុគសម័យ VUCA ។

## ដើម្បីរស់ក្នុងពិភព VUCA នេះ

ដើម្បីរស់រានមានជីវិតនៅក្នុងពិភព VUCA នេះ យើងមិនអាចរស់រានបានតាមរយៈការអប់រំដែលមានគោលបំណងអភិវឌ្ឍសមត្ថភាពដោះស្រាយបញ្ហាឱ្យបានលឿនតាមដែលអាចធ្វើបានដោយសន្មតថា បញ្ហាទាំងនោះអាចដោះស្រាយបាននោះទេ។ ដើម្បីរស់រានមានជីវិតនៅក្នុងពិភព VUCA នេះ ការអប់រំដែលមានគោលបំណងអភិវឌ្ឍនូវសមត្ថភាពក្នុងការដោះស្រាយបញ្ហាកាន់តែលឿនដោយសន្មតថា បញ្ហាទាំងនោះអាចដោះស្រាយបាននោះ គឺនឹងមិនអាចរស់រានបានទេ។ សមត្ថភាពក្នុងការកំណត់នូវបញ្ហាបានយ៉ាងឆាប់រហ័ស កំណត់នូវកត្តាបង្ក ព្រមទាំងភ្ជាប់វាទៅនឹងដំណោះស្រាយត្រូវបានគេហៅថា សមត្ថភាពវិជ្ជមាន។ គេហៅថា សមត្ថភាព «អាចធ្វើបាន»។ សមត្ថភាពនេះមិនមែនគ្មានភាពចាំបាច់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលកើតឡើងនៅក្នុងយុគសម័យ VUCA គឺជាស្ថានភាពមួយដែលស្ថានភាពសកលលោកប្រែប្រួលខ្លាំង ដែលលំបាកក្នុងការទស្សន៍ទាយថា តើនៅពេលណាបញ្ហានឹងកើតឡើង ហើយលើសពីនេះទៅទៀត កត្តាដែលពាក់ព័ន្ធមានភាពស្មុគស្មាញ មិនងាយនឹងយល់ ដូច្នេះលំបាកក្នុងការដោះស្រាយ។ វាគឺជាសមត្ថភាពក្នុងការស៊ូទ្រាំនឹងស្ថានភាពលំបាកដោយមិនបោះបង់ សូម្បីតែពេលប្រឈមមុខនឹងបញ្ហាដែលគ្មានចម្លើយភ្លាមៗ និងពិបាកដោះស្រាយជាមួយក៏ដោយ។

## សមត្ថភាពនៃ «សមត្ថភាពអវិជ្ជមាន»

ទាំងនេះ យើងអាចនិយាយបានថា សមត្ថភាពក្នុងការស៊ូទ្រាំនឹងស្ថានភាពលំបាកដោយមិនបោះបង់គឺជា «សមត្ថភាពអវិជ្ជមាន»។ មូលដ្ឋានគ្រឹះនៃសមត្ថភាពនេះគឺការយល់ចិត្ត និងការច្នៃប្រឌិត ដែលត្រូវបានចាត់ទុកថា មានសារៈសំខាន់ក្នុងការបណ្ដុះតាមរយៈការអប់រំ។ ទាំងនៅក្នុងប្រទេសជប៉ុន និងកម្ពុជា ការអប់រំហាក់ដូចជាទាមទារចម្លើយត្រឹមត្រូវពីកូនសិស្ស និងសិស្សានុសិស្ស ហើយសង្កត់ធ្ងន់លើជំនាញដោះស្រាយបញ្ហា ដែលតែងតែទទួលបានការឱ្យតម្លៃខ្ពស់។ ការគិតបែបនេះក៏មិនត្រូវបានលើកលែងនៅក្នុងថ្នាក់សុខភាពដែរ។ ប៉ុន្តែតើបញ្ហាសុខភាពទាំងអស់សុទ្ធតែអាចដោះស្រាយបានដែរឬទេ ? តាមពិតទៅ បញ្ហាសុខភាពជាច្រើនប្រហែលជាមិនអាចដោះស្រាយបានទេ។ របៀបរស់នៅប្រកបដោយសុខភាពល្អជារឿយៗពិបាកក្នុងការអនុវត្ត ដោយសារតែវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងស្ថានភាពគ្រួសារនិងសហគមន៍ កត្តាសេដ្ឋកិច្ច និងកត្តាបរិស្ថាន។



# បញ្ហាសុខភាពកាន់តែស្មុគស្មាញ និងចម្រុះ

នៅក្នុងយុគសម័យ VUCA បញ្ហាសុខភាពកាន់តែស្មុគស្មាញ និងចម្រុះ បញ្ហាប្រឈមថ្មីៗបានកើតឡើង ហើយការដោះស្រាយបញ្ហាសុខភាពកាន់តែលំបាក។ ដូច្នេះហើយ ក្នុងថ្នាក់សុខភាពនិងការអប់រំសុខភាព វាមានសារៈសំខាន់ណាស់ក្នុងការផ្លាស់ប្តូរពីការសង្កត់ធ្ងន់លើសមត្ថភាពវិជ្ជមាន ដែលជាសមត្ថភាពក្នុងការស្វែងរកចម្លើយត្រឹមត្រូវនិងដោះស្រាយបញ្ហា ទៅជាការអប់រំដែលជំរុញសមត្ថភាពអវិជ្ជមាន ដែលជាសមត្ថភាពក្នុងការតស៊ូដើម្បីដោះស្រាយបញ្ហាប្រឈម។ សមត្ថភាពអវិជ្ជមានគឺជាសមត្ថភាពក្នុងការគិតដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតលើសពីចំណេះដឹងដែលមានស្រាប់ចំពោះបញ្ហាដែលគ្មានចម្លើយត្រឹមត្រូវ និងមិនងាយស្រួលក្នុងការដោះស្រាយ។

គ្រូបង្រៀនមានធម្មជាតិចូលចិត្តកូនសិស្ស និងសិស្សានុសិស្សដែលមានសមត្ថភាព «អាចធ្វើបាន»។ ទោះយ៉ាងណាក៏ដោយ វាមិនមែនភាពអសមត្ថភាពទេដែលជាបញ្ហា។ នៅក្នុងយុគសម័យ VUCA ជាជាងការបណ្តុះទំនោរទៅរកតែចម្លើយត្រឹមត្រូវ និងសមត្ថភាព «អាចធ្វើបាន» របស់សិស្ស ខ្ញុំចង់ឱ្យគ្រូបង្រៀនបណ្តុះសមត្ថភាពអវិជ្ជមានរបស់ពួកគេតាមរយៈការបង្រៀន និងការអប់រំដោយស្រមៃពីអំណាចកប់ជ្រៅនៅក្នុងខ្លួនរបស់ពួកគេ។ ថ្នាក់សុខភាពនិយាយអំពីប្រធានបទសុខភាពដែលគ្មានចម្លើយត្រឹមត្រូវប្រាកដតែមួយ ប៉ុន្តែអាចមានចម្លើយត្រឹមត្រូវផ្សេងៗជាច្រើន ដូច្នេះអាចនិយាយបានថា ពួកគេគឺជាក្រុមគោលដៅដែលសមស្របសម្រាប់ផ្តោតនិងអភិវឌ្ឍសមត្ថភាពអវិជ្ជមាន។

ដើម្បីធ្វើដូច្នេះ យើងត្រូវពិចារណាឡើងវិញនូវក្របខណ្ឌ និងវិធីសាស្ត្រក្នុងការវាយតម្លៃការបង្រៀននិងការអប់រំដែលយើងបានពិភាក្សានៅខាងដើម។ នេះគឺជាកិច្ចការដ៏លំបាកមួយ។ ដូច្នេះ សមត្ថភាពអវិជ្ជមានគឺចាំបាច់សម្រាប់គ្រូឧទ្ទេសក្នុងគម្រោង SHCC នេះ ។





**សាស្ត្រាចារ្យបណ្ឌិត អាសាគីវ៉ា តាកាស៊ី**
**សាស្ត្រាចារ្យ កិត្តិយស ប្រធានគម្រោង SHCC**
**មហាវិទ្យាល័យអប់រំ សាកលវិទ្យាល័យ តូក្យូ ហ្គាគីហ្គេ**
មុខវិជ្ជា៖ សុខភាពសកល សុខភាពផ្លូវចិត្ត សុខភាពសង្គមវិទ្យា
ប្រធានបទការស្រាវជ្រាវ៖ កត្តាកំណត់សង្គមទៅលើសុខភាព សុខុមាលភាពផ្លូវចិត្តរបស់កុមារនិងមនុស្សវ័យជំទង់

NEWSLETTER
School Health Development Project for all Cambodian Children
Supported by THE NIPPON FOUNDATION
Special Edition | 21 August, 2024

# Message from Professor. Asakura Takashi

This special edition is a compilation of Professor Asakura's speech at the opening of the 18th School Health Lecturer Training on July 2024.

## Education to develop negative capability to survive in the VUCA era

Today, I would like to talk about two points: what is the effectiveness of teaching and education, and the evaluation of education and the competencies that should be developed in education. I have observed health classes in nine lower secondary schools as part of a model project conducted by NGO ESC-KIZUNA in Koh Kong Province. The classes were about infectious diseases under the premise that if knowledge is taught, infectious diseases can be prevented.



### How to evaluate the effectiveness of teaching lessons

I would like to share my opinions about evaluation in education and the competencies that should be developed in students and pupils based on my impressions from that visit. The first concerns education, specifically how to evaluate the effectiveness of teaching lessons. Research on lessons aims to find improvements to make teaching better and to ensure that positive effects occur for learners in the classroom. While there are some important questions about “what is a better lesson?” I will talk here about how to evaluate the effects of education that occur on learners, specifically on students and pupils.







On the other hand, direct or indirect classroom observation and hearing the experiences of teachers, pupils, and students could be used to evaluate the effectiveness of the lessons. This requires qualitative lesson evaluation research. This is the process of evaluation. But in the first place, is it possible to ascertain the effects of education and teaching on pupils and students by quantitative or qualitative methods? Is the evaluation perspective based not on the current trends in the educational world, the policy intentions of the educational administration, or the convenience of teachers and schools, but on a perspective that puts the human growth and development of students and teachers first?

## Effectiveness must be "MEASURABLE"?

To evaluate the effectiveness of teaching, education, and learning, it is generally assumed that the effectiveness can be quantified. In other words, it must be "measurable". To do so, it is necessary to create indicators that can quantify the events that indicate effectiveness and make them measurable. Methods for measuring them need to be established. This is the idea of quantitative lesson evaluation research. It is what is called "outcome evaluation".



There must be graspable aspects of the effectiveness of education and teaching that can be measured and narrated, as well as ungraspable aspects that cannot be quantified or narrated. We cannot evaluate education and teaching only by what is easily measurable and appears on the surface as awareness and behavior. It is possible for a student to understand the importance of what he or she learns in a class as he or she grows up, even if he or she did not understand it at the time. Of course, the graspable aspect is important to the evaluation of education, but educators and teachers need to keep both perspectives in mind. With this in mind, we believe it is important not to be satisfied with superficially correct answers given by pupils and students, but to conduct and evaluate lessons while exercising our imagination on what is happening or not happening in their deeper inner world.








For example, if a student answers that wearing long sleeves and long pants is the way to prevent mosquito bites in order to prevent mosquito-borne infections, but he or she is wearing short sleeves, short pants, or a skirt, what is happening inside him or her? If a student answers that it is important to eat adequate nutrition and vegetables to boost immunity, but his or her family's economic situation does not allow him or her to eat a balanced diet and vegetables, what is happening in him or her at that time in terms of classes and education? Health education often faces such contradictions. We need to ask how we can apply these contradictions to our teaching to make it more effective. The other point is about competencies that should be fostered in education and teaching. I will talk about Positive capability and Negative capability.



## In the era of VUCA

Have you ever heard of the letters **VUCA**, V, U, C, and A? These words are made up of the initial letters of English words that symbolize the state of the world today:

- **V** stands for "Volatility", meaning that world affairs are fluid and changeable;
- **U** stands for "Uncertainty", meaning that what will happen in the world in the future is uncertain and unpredictable;
- **C** stands for "Complexity", meaning that what is happening in the world is complicated and difficult to understand due to a variety of factors, and
- **A** stands for "Ambiguity," meaning that the causes and effects of events in the world are unclear.



In Japan and many other Western countries, the competencies they are looking for in the children and young people who will lead the future are competencies that will enable them to survive and better develop society in the age of VUCA.

## To survive in this VUCA world

In order to survive in this VUCA world, it is not possible to survive through education that aims to develop the capacity to solve problems as quickly as possible by assuming that they are solvable. To survive in such a VUCA world, education that aims to acquire the ability to solve problems more quickly by considering them as solvable will not be able to cope. The ability to quickly identify a problem, pinpoint the factors, and link it to a solution is called positive capability. It is the so-called "can-do" ability. This capability is not unnecessary. What happens in the era of VUCA, however, is a situation in which the global situation is so volatile that it is difficult to predict when a problem will arise, and moreover, the factors involved are complex, not easily understood, and therefore difficult to resolve. It is the ability to endure difficult situations without giving up, even when faced with problems that do not have immediate answers and are difficult to deal with.

## Ability of "NEGATIVE CAPABILITY"

It is, so to speak, the ability to endure difficult situations without giving up. This ability is "negative capability." The foundation of this capability is empathy and creativity, which are considered important to nurture through education. In both Japan and Cambodia, education seems to demand correct answers from pupils and students and emphasize problem-solving skills, which are highly valued. This is no exception in health classes. But are all health issues really solvable? In fact, many health problems may not be solvable. Healthy lifestyle habits are often difficult to implement because they are closely related to family and community circumstances, economic factors, and environmental factors.



## Health issues have become more complex and diverse

In the era of VUCA, health issues have become more complex and diverse, new challenges have arisen, and addressing health issues has become more difficult. Therefore, in health classes and health education, it is important to shift from an emphasis on positive capability, which is the ability to seek correct answers and solve problems, to education that fosters negative capability, which is the ability to persevere in tackling challenges. Negative capability is the ability to think of creative solutions beyond existing knowledge to problems that do not have correct answers and are not easy to solve.

Teachers inherently like pupils and students with “can-do” abilities. However, it is not the inability that is the problem. In the era of VUCA, rather than nurturing the superficial correct answers and can-do abilities of pupils and students, I would like teachers to cultivate their negative capability through teaching and education, imagining the power that lies deeper within them. Health classes deal with health topics that do not have one correct answer, but can have a variety of correct answers, so they can be said to be a suitable subject for focusing on and developing negative capability.

To do so, we will need to rethinking the framework and approach to evaluation of teaching and education that we first discussed. This is a difficult task. Therefore, negative capability is needed for SHCC lecturers.





**Asakura Takashi**

**PhD. Professor Emeritus, SHCC Project Leader**
**Faculty of Education, Tokyo Gakugei University**

Field: Global Health, Mental Health, Sociology of Health
Research theme: Social determination of health, Psycho-social well-being of children and adolescents